**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០១ លប**

# លិខិតបញ្ជា

## ស្តីពី

## វិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

កន្លងមក រាជរដ្ឋាភិបាលបានចេញជាបន្តបន្ទាប់នូវអនុក្រឹត្យ លិខិតបញ្ជា ឬសារាចរណែនាំនានាមួយចំនួន ក្នុងគោលបំណងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ជាពិសេសពាក់ព័ន្ធនឹងកិច្ចសហការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធតាមគ្រប់រូបភាព មានជាអាទិ៍ ÷ លិខិតបញ្ជាលេខ ២៣លប ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីវិធានការទប់ស្កាត់អំពើរត់គេចពន្ធនៅតាមច្រកចេញ-ចូលព្រំដែន សារាចរលេខ ០៦សរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទម្រង់សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ប៉ុន្តែរាជរដ្ឋាភិបាលក៏បានសង្កេតឃើញថា ប្រសិទ្ធភាពនៃការទប់ស្កាត់ និងការបង្ក្រាបអំពើរត់គេចពន្ធពុំទាន់ត្រូវបានបង្កើនឱ្យអស់លទ្ធភាពនៅឡើយ។ ក្រៅពីធ្វើឱ្យប៉ះពាល់ដោយផ្ទាល់ដល់ចំណូលថវិការដ្ឋ អំពើរត់គេចពន្ធបានធ្វើឱ្យមានអំពើអយុត្តិធម៌ក្នុងការប្រកួតប្រជែងពាណិជ្ជកម្មថែមទៀត។ ហេតុនេះ វាគឺជាកម្មវត្ថុដ៏ក្តៅគគុកក្នុងក្រសែភ្នែកមហាជន ធុរជន វិនិយោគិន ក៏ដូចជាសហគមន៍អ្នកផ្តល់ជំនួយ និងបណ្តាអ្នកសង្កេតការណ៍ជាតិនិងអន្តរជាតិនានាផងដែរ នាពេលបច្ចុប្បន្ននេះ។

ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធ រាជរដ្ឋាភិបាលសម្រេចចេញបទបញ្ជាដូចខាងក្រោម÷

១- កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងសមត្ថកិច្ចពាក់ព័ន្ធ មានកាតព្វកិច្ចត្រូវគាំទ្រ និងចូលរួមសហការយ៉ាងសកម្មបំផុត ប្រកបដោយភាពស្មោះស្ម័គ្រ និងទាន់ពេលវេលាជាមួយសមត្ថកិច្ចគយនិងរដ្ឋាករ ក្នុងការអនុវត្តន៍ការងារស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ នៅរាល់ពេលដែលសមត្ថកិច្ចនេះ ស្នើសុំការគាំទ្រ និងការចូលរួមសហការជាផ្លូវការ ដោយជៀសវាងការលូកដៃធ្វើកិច្ចការរបស់សមត្ថកិច្ចគយនិងរដ្ឋាករដោយផ្ទាល់។ សមត្ថកិច្ចគយនិងរដ្ឋាករ ត្រូវធ្វើទំនាក់ទំនងចំហរជាផ្លូវការជាមួយអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធដែលត្រូវស្នើសុំកិច្ចសហការ ជៀសវាងការធ្វើទំនាក់ទំនងជាបុគ្គល។ កិច្ចប្រតិបត្តិការនេះត្រូវដំណើរការប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានលក្ខណៈច្បាស់លាស់ស្របតាមទម្ងន់ទ្រាយ ទំហំ និងភាពចាំបាច់នៃករណីនីមួយៗ ដោយចែកចេញជាបីប្រភេទដូចខាងក្រោម÷

១.១- **ប្រភេទទី ១** : គឺជាប្រភេទប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធទ្រង់ទ្រាយធំ ប្រកបដោយការត្រៀមទប់ទល់ និងមានការចាត់តាំងជាខ្សែរយៈគ្រោងទុកជាមុន ដែលអាជ្ញាធរគយនិងរដ្ឋាករ ត្រូវការការគាំទ្រ និងការចូលរួមសហការពីកម្លាំងសរុបអន្តរក្រសួង។ ប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធប្រភេទទី ១ នេះ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មការអន្តរក្រសួងមួយដែលមានសមាសភាពដូចតទៅ÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- អគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- នាយរងសេនាធិការចម្រុះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |
| ៤- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥- ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ | សមាជិក |
| ៦- អនុប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ៧- អគ្គនាយកនៃអគ្គនាយកដ្ឋានកំពង់ផែ | សមាជិក |
| ៨- ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើសនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា | សមាជិក |

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់កងកម្លាំងប្រដាប់អាវុធនិងមធ្យោបាយការងារនានា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័ន ឬអង្គភាពសាមីពាក់ព័ន្ធតាមទំហំសមស្របមួយ ដោយមានការឯកភាពពីប្រធាន តាមការស្នើសុំពីអនុប្រធានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ភារកិច្ចរបស់គណៈកម្មការអន្តរក្រសួងនេះ រួមមាន :

-ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងដឹកនាំការធ្វើប្រតិបត្តិការបង្ក្រាបអំពើល្មើសរត់គេចពន្ធទំនិញគ្រប់ប្រភេទដែលមានទ្រង់ទ្រាយធំ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាទាំងមូល ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន

-ប្រជុំ ធ្វើការបូកសរុប និងវាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយនានានៃការអនុវត្តន៍នូវលិខិតបញ្ជានេះ

-ចាត់តាំង ផ្សព្វផ្សាយ និងជូនដំណឹងឱ្យបានទូលំទូលាយដល់កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធតាមមូលដ្ឋាន និងទីតាំងចាំបាច់នានាឱ្យបានយល់ដឹងនិងស្គាល់កាតព្វកិច្ចរៀងៗខ្លួន ក្នុងការចូលរួមកិច្ចសហការនេះ មានជាអាទិ៍ ការបើកធ្វើសិក្ខាសាលា ការប្រជុំផ្សព្វផ្សាយ ឬតាមរយៈការបោះពុម្ពចែកចាយនូវកម្រងឯកសារច្បាប់ លិខិតបទដ្ឋាន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន

-លើកឡើងនូវបណ្តាវិធានការពង្រឹងបន្ថែម និងកែលំអការអនុវត្តន៍តាមតម្រូវការជាក់ស្តែង ដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធលើទំនិញគ្រប់ប្រភេទឱ្យកាន់តែមានប្រសិទ្ធភាពឡើងជាលំដាប់

-រាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

១.២- **ប្រភេទទី ២** : គឺជាប្រភេទប្រតិបត្តិការ ដែលមានទ្រង់ទ្រាយមធ្យម ប្រកបដោយការត្រៀមទុកជាមុន ដែលអាជ្ញាធរគយនិងរដ្ឋាករត្រូវការការគាំទ្រ និងការចូលរួមពីកម្លាំងកងប្រដាប់អាវុធ ឬអាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ តាមមូលដ្ឋានរាជធានី-ខេត្ត ពាក់ព័ន្ធនីមួយៗ។ ប្រតិបត្តិការបង្ក្រាបអំពើល្មើសគេចពន្ធដែលមានទ្រង់ទ្រាយមធ្យមនេះ ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មការចម្រុះតាមរាជធានី-ខេត្តនីមួយៗ ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត | ប្រធាន |
| ២- ប្រធានសាខាគយ និងរដ្ឋាកររាជធានី-ខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី-ខេត្ត | សមាជិក |
| ៤- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី-ខេត្ត | សមាជិក |
| ៥- ស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត | សមាជិក |
| ៦- ប្រធានសាខាកាំកុងត្រូលរាជធានី-ខេត្ត | សមាជិក |

ក្នុងករណីដែលប្រតិបត្តិការមានទ្រង់ទ្រាយមធ្យមនេះ ប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ឬតាមបណ្ដាខេត្ត ដែលពុំទាន់មានសាខាគយនិងរដ្ឋាករ ប្រធាននាយកដ្ឋានបង្ការនិងបង្ក្រាបបទល្មើស នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវទទួលជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការនេះ ។

គណៈកម្មការចម្រុះនេះ មានសិទ្ធិប្រើប្រាស់កងកម្លាំងប្រដាប់អាវុធ និងមធ្យោបាយការងារនានា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គភាពសាមីពាក់ព័ន្ធ តាមទំហំសមស្របមួយ ដោយមានការឯកភាពពីប្រធាន តាមការស្នើសុំពីអនុប្រធានអចិន្ត្រៃយ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលារាជធានី-ខេត្តសាមីនីមួយៗ ។

ភារកិច្ចរបស់គណៈកម្មការចម្រុះនេះតាមរាជធានី-ខេត្ត រួមមាន:

- ចាត់វិធានការស្រាវជ្រាវ ទប់ស្កាត់ និងដឹកនាំការបង្ក្រាបអំពើល្មើសរត់គេចពន្ធទំនិញគ្រប់ប្រភេទ ដែលមានទ្រង់ទ្រាយមធ្យមតាមមូលដ្ឋានរាជធានី-ខេត្តសាមី ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន
- ប្រជុំ ធ្វើការបូកសរុប និងវាយតម្លៃចំណុចខ្លាំង ចំណុចខ្សោយនានានៃការអនុវត្តនូវលិខិតបញ្ជានេះ និងលើកវិធានការអនុវត្តបន្ត
- រាយការណ៍អំពីលទ្ធផលការងារ ដែលសម្រេចបានជូនគណៈកម្មការអន្តរក្រសួងខាងលើ ដោយចម្លងជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទីស្ដីការគណៈរដ្ឋមន្ត្រី ។

១.៣- **ប្រភេទទី ៣** : គឺជាប្រភេទប្រតិបត្តិការស្រាវជ្រាវពួនស្ទាក់ ជាលក្ខណៈបន្ទាន់បំផុតក្នុងការតាមដានប្រកិត ជាលក្ខណៈបទល្មើសជាក់ស្ដែង និងការដេញតាមភ្លាម ដែលអាជ្ញាធរគយនិងរដ្ឋាករ ត្រូវការការចូលរួមគាំទ្រ និងសហការជាបន្ទាន់បំផុតពីកងកម្លាំងប្រដាប់អាវុធគ្រប់អង្គភាព ឬអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ដែលកំពុងឈរជើងបំពេញភារកិច្ច ឬកំពុងស្ថិតនៅក្នុងទីជិតបំផុតនៃកន្លែងកើតហេតុនីមួយៗ។ កងកម្លាំងប្រដាប់អាវុធ ឬអាជ្ញាធរដែនដីមានកាតព្វកិច្ចត្រូវគាំទ្រនិងចូលរួមសហការជាបន្ទាន់តាមការស្នើសុំនេះ ដោយពុំចាំបាច់រង់ចាំការអនុញ្ញាត ឬបទបញ្ជាណាផ្សេងក្រៅពីលិខិតស្នើសុំការគាំទ្រ និងសហការជាផ្លូវការរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដែលនឹងកំណត់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

២- កងកម្លាំងប្រដាប់អាវុធគ្រប់អង្គភាព អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដែលបានពិនិត្យឃើញនូវបទល្មើសគយជាក់ស្ដែងនានា ត្រូវជូនដំណឹងជាបន្ទាន់ដល់សមត្ថកិច្ចគយនិងរដ្ឋាករ ដែលកំពុងឈរជើងបំពេញភារកិច្ចនៅកន្លែងជិតបំផុតនៃកន្លែងកើតហេតុ ដើម្បីសហការឃាត់ទុកជាបណ្ដោះអាសន្ននូវមធ្យោបាយដឹកជញ្ជូននិងទំនិញល្មើសនេះ និងចូលរួមធ្វើកំណត់ហេតុល្មើសច្បាប់គយ តាមទម្រង់ និងនីតិវិធីជាធរមាន។ ដោយឡែក ទំនិញនិងមធ្យោបាយដឹកជញ្ជូន ត្រូវចាត់ចែងបញ្ជូនជាបន្ទាន់ តាមដែលអាចធ្វើទៅបាន ទៅកាន់ការិយាល័យគយនិងរដ្ឋាករ ដែលនៅជិតបំផុតដើម្បីថែរក្សា គ្រប់គ្រង រង់ចាំការសម្រេចវិនិច្ឆ័យតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន ពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

៣- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុករ៉ាប់រងនូវការចំណាយចាំបាច់នានា ក្នុងប្រតិបត្តិការនីមួយៗ ក៏ដូចជាការចំណាយសម្រាប់ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តផ្សេងៗ ចំពោះប្រតិបត្តិករដែលបានចូលរួម ដោយមានសិទ្ធិប្រើប្រាស់ទឹកប្រាក់នៃផលដែលបានមកពីប្រតិបត្តិការបង្ក្រាបនីមួយៗ ដែលត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងករណីទឹកប្រាក់ដែលត្រូវផ្តល់រង្វាន់លើសពី ១០០លានរៀល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវសុំយោបល់សម្រេចពីប្រមុខរាជរដ្ឋាភិបាល ។

៤. បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីលិខិតបញ្ជានេះ ត្រូវចាត់ទុកជានិរាករណ៍។

ទទួលបានលិខិតបញ្ជានេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ អភិបាលនៃគណៈអភិបាលខេត្ត និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវអនុវត្តតាមខ្លឹមសារខាងលើឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- សាលារាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ